# ជំងឺដុំពកស្បែក គោក្របី (LSD)

- កើតមានឡើងលើគោ និងក្របី តែប៉ុណ្ណោះ។
- មិនឆ្លងទៅមនុស្សឡើយ។
- ជំងឺកើតមានឡើងតាមរដូវកាលជាពិសេសនៅរដូវវស្សាដែលមានពពួកសត្វល្អិតច្រើន (ដែលជាភ្នាក់ងារចម្លងមេរោគ)។
- បង្កឱ្យមានការខាតបង់ធ្ងន់ធ្ងរដល់ការចិញ្ចឹមគោក្របី ដោយសារការខូចស្បែក បញ្ហាបង្កកំណើត រលូត ការថយចុះទម្ងន់ បរិមាណទឹកដោះថយចុះខ្លាំង និងក្នុងករណីខ្លះបណ្តាលឱ្យងាប់តែម្តង។
- រាំងស្ទះក្នុងការធ្វើពាណិជ្ជកម្ម (លក់-ដូរ) និងការខាតបង់ដោយការអនុវត្តវិធានជីវសុវត្ថិភាព។



គោឆ្លងជំងឺធ្ងន់ធ្ងរ ដែលឡើងដំបៅស្បែកច្រើនកន្លែង © BFSA/Tsviatko Alexandrov

## ការចម្លងជំងឺ

- ភាគច្រើនឆ្លងតាមសត្វល្អិត ដូចជា មូស តាប៉ោម មាននៅក្នុងក្រោល។
- តាមរយៈការនាំគោក្របីដែលមានជំងឺពីតំបន់ផ្សេង។
- អាចឆ្លងតាមរយៈការស៊ីចំណីនិងផឹកទឹករួមគ្នា ទឹកដោះ ការបង្កាត់ពូជ ការព្យាបាល (បើមិនដូរម្ជុល) ឬការប៉ះពាល់ផ្ទាល់។

## ភាពធន់របស់មេរោគ

- នៅ៦៥ºC រស់បាន៣០នាទី ក្នុងទឹករងៃនៅ៤ºC រស់បាន ៦ខែ នៅសីតុណ្ហភាព -៨០ ºC មេរោគអាចរស់នៅបានរហូត១០ឆ្នាំ។
- មិនធន់នឹងជាតិអាស៊ីតឬបាសទេ។ ឆាប់ងាប់នឹងទឹកសាប៊ូ និងសារជាតិសម្លាប់មេរោគដូចជា ផេណុល (២%) ហ្វ័រម៉ាលីន (១%) Virkon® (2%) quarternary ammonium compounds (0,៥%) សូដ្យូមអ៊ីប៉ូក្លរីត (២-៣%)។

## ភាពធន់របស់មេរោគ

- វីរុសមានភាពធន់ខ្លាំងនិងអាចរស់នៅបានយូរក្នុងបរិស្ថាន។ រស់នៅក្នុងដុំពកស្បែករលួយបានរហូតដល់៣៣ថ្ងៃឬយូរជាងនេះ ក្រមរស្ងួតបាន៣៥ថ្ងៃនិងក្នុងស្បែកស្ងួតបានយ៉ាងតិច១៨ថ្ងៃ។ វីរុសងាយងាប់ដោយសារពន្លឺព្រះអាទិត្យ និងសាប៊ូ ប៉ុន្តែវាអាចរស់នៅបានជាច្រើនខែក្នុងក្រោលដែលគ្មានពន្លឺចេញចូល។

## រោគសញ្ញា

រយៈពេលសំងំជំងឺមានរហូត២៨ថ្ងៃ ហើយនឹងបង្ហាញរោគសញ្ញាដូចខាងក្រោម៖

- ក្តៅខ្លួនខ្លាំង (ពី៤០ ទៅ ៤១ ºC) បាត់បង់ការស៊ីចំណី និងបរិមាណទឹកដោះថយចុះ។
- មានដុំពកលើស្បែករាងមូល(រឹងឬទន់) ប្រវែងពី១ទៅ៥ស.ម. ជាធម្មតាដំណាក់កាលដំបូងឃើញមានលើក្បាល និងក។ លក្ខណៈនេះពិបាកសម្គាល់ ចំពោះគោក្របីដែលមានរោមវែង ដែលតម្រូវឱ្យយើងស្ទាបផ្ទាល់ ឬអាចមើលឃើញនៅពេលរោមសើម។
- ចំនួនដុំពកនៅលើស្បែកប្រែប្រួលពីតិចទៅច្រើនទៅតាមស្ថានភាពជំងឺពីស្រាលទៅធ្ងន់ធ្ងរ។
- ដុំពកអាចរាបទៅវិញទៅតាមការវិវត្តន៍នៃជំងឺហើយក្លាយជាក្រមរនិងដំបៅជ្រៅនៅផ្នែកកណ្តាល ដែលទាក់ទាញពពួកសត្វល្អិតជាខ្លាំងដូចជាមូស និងរុយជាដើម។
- ដំបៅមាត់និងច្រមុះ (ក្នុងនិងក្រៅ) និងបបូរមាត់។
- ហៀរទឹករងៃចេញពីភ្នែកនិងច្រមុះនិងហៀរទឹកមាត់ច្រើន។
- ហើមកូនកណ្តុរ (ជាពិសេសនៅលើផ្នែកស្មា និងភ្លៅ)។
- សត្វខ្លះមិនបង្ហាញរោគសញ្ញាទេតែផ្ទុកមេរោគក្នុងឈាមដែលអាចចម្លងទៅសត្វផ្សេងទៀតតាមរយៈសត្វល្អិតខាំ ឬបឺត។




រូបភាពបង្ហាញពីការឆ្លងរាលដាលជំងឺដុំពកលើស្បែក គោ ក្របី

## រោគវិនិច្ឆ័យ

- ការធ្វើរោគវិនិច្ឆ័យបឋមនៅលើវាល ផ្អែកជាសំខាន់លើសញ្ញាគ្រុនក្តៅ និងការលេចចេញជាដុំពក។
- ការធ្វើតេស្តបញ្ជាក់នៅមន្ទីរពិសោធន៍ជាការចាំបាច់ពីសំណាកមានដូចជាដំបៅស្បែក ក្រមរ ឈាម (ដាក់ថ្នាំកុំឱ្យកក EDTA) ឬតំបារទឹកមាត់។ ក្រមរ ជាសំណាកដ៏ល្អដោយអាចដឹកជញ្ជូនមិនចាំបាច់ប្រើសារជាតុថែរក្សា។



...ដែលនាំឱ្យរលាត់ស្បែក រលាក និងមានសន្លាក © BFSA/Tsviatko Alexandrov

## ការព្យាបាល

ជំងឺនេះបង្កដោយវីរុសហើយពុំមានថ្នាំអាចព្យាបាលមានប្រសិទ្ធភាពទេ។ ការព្យាបាលបំបាត់រោគសញ្ញាអាចជួយបានដូចជាការប្រើប្រាស់ថ្នាំបំបាត់ការឈឺចាប់និងរលាក រួមផ្សំជាមួយថ្នាំផ្សះដើម្បីកំចាត់ពួកបាក់តេរីដែលឆ្លងចូលតាមក្រោយ។

## ការចាក់វ៉ាក់សាំង

- វ៉ាក់សាំងមានប្រសិទ្ធភាពអាចការពារបានបន្ទាប់ពីចាក់បាន៣សប្តាហ៍។
- គួរចាក់វ៉ាក់សាំងឱ្យគោក្របី នៅមុនពេលដែលហ្វូងគោក្របីទាំងមូលឆ្លងជំងឺ។
- អាចមានប្រតិកម្មតិចតួចក្រោយពេលចាក់រួចដូចជា៖
  - ហើមនៅកន្លែងចាក់ តែមិនបង្កគ្រោះថ្នាក់នោះ និងអាចបាត់ទៅវិញក្នុងរយៈពេលពី ១ ទៅ ២ សប្តាហ៍។
  - គ្រុនក្តៅមួយរយៈពេលខ្លី។
  - ក្នុងករណីកម្រ វ៉ាក់សាំងមួយចំនួនអាចបណ្តាលឱ្យមានស្នាមកន្ទួលតូចនៅលើខ្លួន ឬដោះ តែអាចបាត់ទៅវិញនៅក្នុងរយៈពេលខ្លី។



ដំបៅរលាកនៅចុងដោះ © BFSA/Tsviatko Alexandrov

## ពិនិត្យនិងតាមដានគោក្របី និងរាយការណ៍ពីករណីសង្ស័យ

- ត្រូវពិនិត្យនិងតាមដានគោក្របីជារៀងរាល់ថ្ងៃក្នុងអំឡុងពេលផ្ទុះជំងឺ ឬ នៅក្នុងតំបន់ដែលមានហានិភ័យនៃជំងឺ។
- ត្រូវរាយការណ៍អំពីករណីសង្ស័យណាមួយជាបន្ទាន់។
- ជូនដំណឹងដល់ទៅកសិករចិញ្ចឹមសត្វនៅតំបន់ជុំវិញសង្ស័យផ្ទុះជំងឺសត្វ ឬអ្នកដែលបានទិញ-លក់សត្វថ្មីៗដើម្បីឱ្យពួកគាត់ត្រួតពិនិត្យនិងតាមដានសត្វដែលបានទិញ-លក់ថ្មីៗទាំងនោះ។
- ត្រូវបញ្ឈប់ចរាចរសត្វគោក្របីជាបន្ទាន់ក្នុងករណីមានការសង្ស័យពីជំងឺដុំពកលើស្បែកគោក្របី។

## តើត្រូវការពារកន្លែងចិញ្ចឹមគោក្របីយ៉ាងដូចម្តេច?

- ការចាក់វ៉ាក់សាំង៖ការចាក់វ៉ាក់សាំងដែលមានប្រសិទ្ធភាពបន្ទាប់ពីចាក់បាន ៣ សប្តាហ៍។
- ទិញគោក្របីពីប្រភពដែលអាចទុកចិត្តបានគ្មានជំងឺ។ សត្វនាំចូលថ្មីត្រូវពិនិត្យឱ្យបានច្បាស់មុនបម្លាស់ទី និងនៅពេលយកមកដល់កន្លែងចិញ្ចឹម ហើយគួរធ្វើចត្តាឡីស័កយ៉ាងតិច២៨ថ្ងៃ។ ក្នុងករណីមានផ្ទុះនៃជំងឺនេះក្នុងតំបន់ មិនត្រូវលក់ ទិញ ឬនាំសត្វថ្មីចូលទេ។
- ប្រើប្រាស់ថ្នាំកម្ចាត់ ឬបណ្តេញសត្វល្អិត (មូស រុយ ដង្កែ...) ឱ្យបានទៀងទាត់ តាមរយៈការលាប បាញ់ ឬ ប្រើប្រាស់ថ្នាំនៅនឹងកន្លែង។
- សម្អាតកន្លែងចិញ្ចឹមសត្វកុំឱ្យមានដក់ទឹក លាមក និងសម្រាមដើម្បីកាត់បន្ថយការកកើតនៃពពួកមូស រុយ និងសត្វល្អិតផ្សេងៗ។
- កុំអនុញ្ញាតឱ្យអ្នកផ្សេងចូលក្នុងកន្លែងចិញ្ចឹមសត្វ។ ក្នុងករណីចាំបាច់ត្រូវគោរពតាមវិធានជីវសុវត្ថិភាពឱ្យបានត្រឹមត្រូវ។ រាល់យានជំនិះ ឧបករណ៍ សម្ភារៈ និងស្បែកជើងជាដើម ត្រូវលាងសម្អាតដោយទឹកសាប៊ូ ឬថ្នាំសម្លាប់មេរោគ។
- ត្រូវបំបែកសត្វឈឺចេញពីសត្វជា។ ក្នុងករណីធ្ងន់ធ្ងរខ្លាំងគួរសម្លាប់សត្វ ដើម្បីជៀសវាងការឆ្លងរាលដាលធ្ងន់ធ្ងរទៅសត្វផ្សេងទៀត។

## ក្នុងករណីមានការសង្ស័យជំងឺដុំពកស្បែកគោក្របីដែលមានរោគសញ្ញាដូចជា៖

- ✓ ដុំពកតូច ឬធំនៅលើស្បែកដងខ្លួន កញ្ចឹងក ច្រមុះ ប្រដាប់ភេទ និងកន្សោមដោះ។ល។ ដុំពកនេះដំណាក់កាលបន្ទាប់នឹងក្លាយជាដំបៅហើយមានក្រមរ។
- ✓ សត្វក្តៅខ្លួនរហូតដល់៤១ ºC

☞សូមរាយការណ៍ជាបន្ទាន់តាមទំនាក់ទំនងដូចខាងក្រោម៖

- ➢ ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត
- ➢ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
  - លោក ទុំ សុធ្វីរ៉ា ទូរស័ព្ទ: ០១២ ៩៥២ ៥១៨
  - លោក នូ វនិកា ទូរស័ព្ទ: ០១២ ៤៨៣ ៥៧៨
  - លោក សុខ ដារ៉ូ ទូរស័ព្ទ: ០៧៨ ៥៥៥ ៦៨៩
  - លោក ធិ មករា ទូរស័ព្ទ: ០៩២ ៦០២ ៩៩៧<br>០១០ ៩៧៨ ១៩២<br>០៨៨ ៥០០ ០៧២៥

**ព័ត៌មានលម្អិតអំពីជំងឺសូមចូលទៅគេហទំព័រ៖**

http://www.fao.org/3/a-i7330e.pdf




Food and Agriculture Organization of the United Nations

# ជំងឺដុំពកស្បែក (LSD)

## សម្រាប់បសុពេទ្យ

"ការបកប្រែនិងបោះពុម្ពអត្ថបទនេះ អាចធ្វើទៅបានដោយមានការគាំទ្រពីការិយាល័យជំនួយមនុស្សធម៌ នៃទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិក្រោមកិច្ចសន្យាលេខ 720FDA20IO00029។

ទស្សនៈយោបល់ដែលលើកឡើងក្នុងឯកសារនេះគឺជាទស្សនៈយោបល់របស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិឡើយ។"